វគ្គទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោរពផ្ញើរជូនកម្មវិធីកូនខ្មែរពិត

សូមលំអោនកាយ គោរព និងជំរាបសួរ ប្រិយមិត្តអ្នកស្តាប់ទាំងអស់

មួយរយៈពេលខ្លី នៃការសន្យារបស់ខ្ញុំបានវិលមកដល់ ។ អ្នកទាំងអស់គ្នានៅចាំជីវិតក្មេងកំព្រាដ៏កំសត់ម្នាក់នេះបានទេ? ប្រហែលជាមានអ្នកនៅចងចាំខ្លះៗហើយមើលទៅ?តើលោកអ្នកទាំងអស់គ្នាសុខសប្បាយជាទេ? លិខិតលើកនេះខ្ញុំគិតថានិងបានលឺជាលើកទី២ទៀត ។ហើយសូមអ្នកមេត្តាកុំធុញទ្រាន់ក្នុងការស្តាប់អីណាព្រោះពេលខ្លះវាពិតជាអាចជួយផ្តល់អោយនូវមេរៀនជីវិតដែលអ្នកកំពុងតែជួបប្រទះ និង ត្រូវឆ្លងកាត់ ដោយការ តស៊ូ អំណត់ ព្យាយាមហើយអ្វីៗដែលជាការតាំងចិត្តរបស់អ្នកវាប្រាកដ និងបានសំរេចក្នុងពេលអនាគត ។ខ្ញុំសូមបន្តនូវដំណើរជីវិតរបស់ខ្ញុំបន្ទាប់ពីបានបង្ហាញការពិតខ្លះៗតាមរយៈសំណេរវគ្គ១នៃវិទ្យុ៨៨ នេះដែលលិខិតមានចំណងជើងថា: **តើខ្ញុំជាអ្នកណា?**

ក្នុងកំឡុងពេលនៃការរស់នៅក្នុងគីឡូម៉ែត្រលេខ៧បានរយៈពេលជិត៣ឆ្នាំខ្ញុំបានរៀនឡើងដល់ថ្នាក់ទី២ ប៉ុន្តែស្ថានភាពគ្រួសារ របស់ខ្ញុំកាន់តែដុនដាបទៅៗ ធ្វើអោយពួកយើងត្រូវដាច់បាយជាញឹកញាប់ ។ ពេលខ្លះខ្ញុំបានក្លាយជាក្មេងដើររើសចំណីអាហារដែលគេបោះបង់ចោលមកទទួលទាន ។ លោកតា លោកយាយ គាត់មានការខ្លោចផ្សា អាណិតអាសូរចំពោះចៅគាត់ម្នាក់នេះណាស់ដែលតែងតែឈរសំលឹងមើលក្មេងៗដទៃទៀតមានចំណីអាហារហូបរត់ប្រលែងគ្នាលេងយ៉ាងសប្បាយចំណែកចៅគាត់បានត្រឹមតែលេបទឹកមាត់ដោយការស្រេកឃ្លាន និង ចង់បាន ។

ហ៊ឺ !រហូតមកដល់បច្ចុប្បន្ននេះហើយក្តីតែទឹកភ្នែកដែលលោកតា លោកយាយបានសំរក់ចេញពីកែវភ្នែកជ្រែកលើផែនថ្ពាល់ដ៏សែនជ្រីវជ្រួញរបស់គាត់វាបានដក់ជាប់ក្នុងអារម្មណ៏របស់ខ្ញុំ គ្រប់ពេលវេលា ។ មកដល់ពេលនេះទើបខ្ញុំដឹងថា តំលៃនៃទឹកភ្នែករបស់អ្នកមានគុណវាមានទំហំធំធេងប៉ុណ្ណា ហើយការសំរក់ទឹកភ្នែករបស់ពួកគាត់គឺគ្មានអ្វីសោះឡើយ ក្រៅពីការអាណិតអាសូរអនិច្ចាវាសនា ដែលផ្តល់អោយនូវទុក្ខវេទនាចំពោះកូនចៅរបស់លោកតែប៉ុណ្ណោះ ។ ខ្ញុំចង់បញ្ជាក់ថានៅលើលោកនេះគ្មានអ្នកណាស្រលាញ់អ្នកជាង អ្នកមានគុណរបស់អ្នកនោះទេ ដូច្នេះសូមអ្នកទាំងអស់គ្នាតបស្នងសងគុណលោកអោយអស់ពីចិត្តដូចដែលអ្នកកំពុងតែស្រលាញ់កូនរបស់អ្នក ។ ហើយប្រសិនបើលោកអ្នកធ្លាប់បានជួបប្រទះនូវរឿងរ៉ាវដូចដែលខ្ញុំនិយាយបែបនេះ ពិតជា

អាណោច អាធិម និង នឹកឃើញនូវអនុស្សាវរីយ៍ឬក៏កំហុសដែលបានធ្វើកន្លងមកចំពោះអ្នកមានគុណ ។ ហើយអ្នកប្រាកដជាសំរក់ទឹកភ្នែកស្រម័យឃើញនូវរឿងអតីតពិតនៅនិងភ្នែកស្លុងគំនិតគិតថាអតីតកាលពិតជាយ៉ាងនេះមែនសំរាប់ពួកយើង ។ វាពិតជាមិនទាន់ហួសពេលទេសំរាប់អ្នកទាំងអស់គ្នា អ្នកគួតែធ្វើដើម្បីរូបអ្នកនិងជាគំរូសំរាប់កូនអ្នក និង អ្នកដ៏ទៃ ។ និយាយពីខ្ញុំវិញ

ថ្ងៃមួយមានភ្លៀងធ្លាក់និងខ្យល់រន្ទះយ៉ាងខ្លាំង តែខ្ញុំមិនទាន់បានហូបអ្វីសោះឡើយ ។ ដោយសារការស្រេកឃ្លានពេក ខ្ញុំបានបែកគំនិតបង្ខំចិត្តដើរចេញទាំងភ្លៀងក្នុងបំណងលួចរបស់មកទទួលទាន ។ ខ្ញុំបានចូលផ្ទះជនជាតិខ្មែរឥស្លាមម្នាក់ហើយបានលួចយកត្រីអាំងរបស់គាត់ដែលដាក់កញ្ច្រែងទុកចោលក្រោមផ្ទះ ។ ខ្ញុំមិនមែនជាមនុស្សដែលគួរអោយស្អប់ខ្ពើមបែប នេះទេ តែដោយសារតែភាពអត់ខ្ញុំត្រូវតែធ្វើ ដើម្បីសំរន់ក្រពះដែលមិនទាន់បានទទួលអ្វីសោះតាំងពីព្រឹកព្រលឹម ។ មឹងជាម្ចាស់ត្រីគាត់បានដឹងហើយ ខឹងយ៉ាងខ្លាំងគាត់ដើរសំដៅមកខ្ទមទាំងមេឃកំពុងបង្អុលភ្លៀងដើម្បីប្រាប់លោកយាយដែលកំពុងតែអង្គុយនៅក្នុងខ្ទមគេចចេញពីតំណក់ទឹកភ្លៀងដែលហូរស្រក់ពីដំបូល ។ លោកយាយមិនបានដឹងទេថាខ្ញុំ បានលួចត្រីរបស់គេព្រោះខ្ញុំបានយកវាមកលាក់ក្រោមគ្រែដែលគាត់សំរាន្ត ។គាត់បានសូមទោសគេដោយញ័រមាត់ហើយប្រាប់ថាចាំគាត់រកយកទៅអោយវិញ ។ ខ្ញុំបានស្តាប់លឺដូច្នោះហើយក៏បានចូលទៅជួបគាត់ទាំងភ័យរន្ធត់ ខ្ញុំបានលើកដៃសំពះអង្វ សូមទោសនិងយកត្រីអាំងអោយគាត់វិញ ។មឹងម្ចាស់ត្រីគាត់បានមើលមកយើងដោយក្រសែភ្នែកអាណិត អាសូរ ។ដោយសារគាត់ឃើញពួកយើងវេទនាខ្លាំងពេកគាត់មិនបានថាអ្វីទេហើយគាត់ថែមទាំងបានកាច់កន្ទុយត្រីអោយពួកយើងទុកទទួលទានទៀតផង ។ម្ចាស់ត្រីបានត្រឡប់ទៅផ្ទះគាត់វិញ ។ លោកយាយបានបែមុខមករកខ្ញុំដោយគ្មាននិយាយអ្វីមួយម៉ាត់សោះឡើយក្រៅពីការសំរក់ទឹកភ្នែកទទួលយកនូវក្តីអាម៉ាស់និងភាពឈឺចាប់ដែលចៅរបស់គាត់បានផ្តល់អោយ ។ខ្ញុំបានលុតជង្គង់សូមទោសគាត់ទាំងខ្លួនទទឹកជោកហើយនិយាយទៅកាន់គាត់ថា ខ្ញុំខុសហើយយាយ សូមយាយកំខឹងនិងខ្ញុំអី  ខ្ញុំឃ្លានណាស់ហើយខ្ញុំមិនទាន់បានអីហូបតាំងពីព្រឹក ។

ខ្ញុំបានអង្វយាយអោយគាត់ឈប់យំ  ហើយខ្ញុំបានសន្យាជាមួយយាយថាខ្ញុំឈប់ប្រព្រឹត្តអំពើរបែបនេះទៀតហើយខ្ញុំនិងខំប្រឹងប្រែងប្រែក្លាយខ្លួនខ្ញុំអោយទៅជាមនុស្សដែលមានតំលៃសំរាប់ថ្ងៃអនាគតខាងមុខ ។ លោកយាយហើយនិងខ្ញុំបានស្រវាអោបគ្នាអង្គុយយំទាំងខ្លួនរងាញ័រចំប្រំ ។ យើងគ្មានសំលេងអ្វីទៀតក្រៅ

អំពីការខ្សឹកខ្សួលអួលដើមកដែលជីវិតជាជនក្រីក្រត្រូវបានទេវតាចាអោយទទួលតែនូវរឿងបែបនេះជៀសមិនរួច ។សំលេងយំរបស់យាយបានសរបញ្ជាក់អោយឃើញនូវក្ដីអាណិតអាសូជាពន់ពេកចំពោះចៅដែលគាត់មិនអាចផ្ដល់អោយបានដូចអ្នកដទៃសូម្បីតែចំណីអាហាមួយចំអែតក្រពះ ។តែទោះជាអាម៉ាស់ប៉ុណ្ណាក៏ពួកយើងបានហូបនូវសំឡរប្រហើកន្ទុយត្រីនោះទាំងគ្មានឱជារសព្រោះតែឆ្អែតចិត្តនិងភាពក្រីក្រ នេះហើយចាការចងចាំគ្មានថ្ងៃបំភ្លេចរបស់ខ្ញុំ ។ប្រសិនបើបច្ចុប្បន្ននេះលោកអ្នកជួបទុក្ខវេទនាដូចខ្ញុំក្នុងអតីតកាលសូមមេត្តាកុំប្រព្រឹត្តអោយដូចខ្ញុំក្នុងពេលនោះអី ពីព្រោះការលួចរបស់ទ្រព្យគេវាមិនធ្វើអោយយើងមានសេចក្ដីសុខសោះឡើយ ទាំងផ្លូវកាយនិងផ្លូវចិត្ត ។ខ្ញុំដឹងថាពេលនោះខ្ញុំពិតជានៅតូចតែរសជាតិនៃជីវិតខ្ញុំពិតជាបានស្គាល់យ៉ាងច្រើនលើសលប់ ។តាំងពីខ្ញុំមាននៅអាយុប្រហែលជាប្រាំបី ឬ ប្រាំបួនឆ្នាំ តែខ្ញុំបានសច្ចាក្នុងចិត្តថាខ្ញុំនិងឈរអោយនឹងមិនត្រូវចុះចាញ់និងវាសនាហើយខ្ញុំក៏មិនដែលតវ៉ានិងព្រហ្មលិខិតដែល ។

តែបើយើងក្រឡេកមកបច្ចុប្បន្នកាលនេះវិញខ្ញុំពិតជាមានអារម្មណ៏សង្វេកចិត្តឥតឧបមាដែលមានអស់លោកមួយចំនួនធំបានរស់នៅហូបចុកសំបូរហូរហៀរក្នុងផ្ទះដ៏សែនធំល្វឹងល្វើយ ។តែបែជាគួអោយអនិច្ចាមនុស្សមួយចំនួនតូច ត្រូវរស់នៅតាមជញ្ជើមថ្នល់ តាមសំយ៉ាបផ្ទះគេ តាមរបងវត គ្មានខ្មើយគ្មានភួយ ហាលខ្យល់ហាលភ្លៀងកំព្រា រងាឯការគ្មានទិសដៅពិតប្រាកដហើយបានដើររើសចំណីអាហារដែលជាកាកសំណល់របស់គេមកទទួលទានទេវិញ ។ហើយកាកសំណល់ទាំងនោះគឺជា របស់ដែលលោកអ្នកទទួលទានមិនអស់ហើយបានគ្រវាត់វាចោល ។ តែវាបែជាមានតំលៃមិនអាចកាត់ថ្លៃបានសំរាប់ជនអនាថាទាំងឡាយទេវិញ ។ វាពិតជាគួអោយអនិច្ចាណាស់មែនទេ? នូវពេលដែល លោកអ្នកបានទិញនូវសត្វដែលមានតំលៃថ្លៃមកចិញ្ចឹមហើយផ្ដល់នូវចំណីអាហារដែលមានតំលៃនិងឱជារសអោយពួកវាស៊ីថែមទាំងមានអ្នកថែទាំទៀតផងនោះ!

តែលោកអ្នកបែជាមើលរំលងនូវជីវិតជនទុរគតទាំងឡាយជាពិសេសជនចាស់ជរាដែលពួកមិនធ្លាប់បានស្គាល់សោះឡើយនូវអ្វីទៅដែលហៅថារបស់មានតំលៃ អ្វីទៅដែលហៅថាមានរសជាតិឆ្ងាញ់ពិសារ ។ ជីវិតរបស់ពួកគេ គឺជា មានតំលៃស្មើគ្នាដូចជាយើងដែល តែគ្រាន់តែទេវតាមិនបានមេត្តាដល់ពួកគេតែប៉ុណ្ណោះ ។ សូមអ្នកអាណិត អាសូរ និងជួយពួកគេផងព្រោះគេពិតជាត្រូវការណាស់នូវជំនួយរបស់អ្នក ។ សូមអ្នកសាកគិតប្រមើមើលថាប្រសិនបើ មាន ខ្យល់ មានភ្លៀង ផ្គរ រន្ទះ តើពួកគេ រងារ យ៉ាងណា? ខ្លាចយ៉ាងណា? ឃ្លានយ៉ាងណា?ដេកកន្លែងណា? តើត្រូវរត់ទៅជ្រកកោននៅទីណា? ពួកគេពុំមានលទ្ធិភាពធ្វើអោយដូចអ្នកបានទេ ។ ពួកគេទាំងនោះកំពុងតែរស់ហែលឆ្លងសមុទ្រមហាសាគរនៃភាពអត់ឃ្លានគ្មានថ្ងៃបានស្គាល់

ឡើយពាក្យថា សុខ ។ តែលោកអ្នកប្រហែលជា មិនជឿទេ ព្រោះលោកអ្នកពុំធ្លាប់ជួបប្រទះនូវភាពលំបាកវេទនាបែបនេះ តែសូមអ្នកជឿចុះថានេះហើយជាភាពពិតនៃជីវិតជាជនក្រីក្ររបស់មនុស្សលោក ។ ខ្ញុំមិនមានចេតនាបន្ទោសឬច្រណែនសោះឡើយចំពោះលោកអ្នកដែលជាអ្នកមាន ។ព្រោះខ្ញុំគិតថាលោកអ្នកក្លាយជាអ្នកមានបានក៏ដោយសារការខំប្រឹងប្រែងរបស់អស់លោកដែល ។ប៉ុន្តែសូមអ្នកសាកល្បងគិតនិងពិចារណាឡើងវិញមើលថា តើមនុស្សយើងម្នាក់ៗអាចយកអ្វីខ្លះត្រឡប់ទៅតាមខ្លួនវិញបានពេលដែលពួកយើងចាស់ជរាទៅ ហើយនិងដល់ពេលវេលាដែលត្រូវស្លាប់នោះ? គឺពិតជាគ្មានទេមែនទេ? គឺមានតែកេរ៍ឈ្មោះរបស់អ្នកប៉ុណ្ណោះ ដែលបន្សល់ទុកបាន ដូច្នេះសូមអ្នកផ្តល់ និង ធ្វើ នូវ អំពើល្អរបស់អ្នកបន្ថែមទៀតតាមដែលលទ្ធិភាពដែលអាចធ្វើទៅបាន ហើយវាថែមទាំងជួយអោយអ្នកទទួលបាននូវអារម្មណ៍ថាអ្នកជាមនុស្សគួរអោយគោរពស្ញប់ស្ញែងនិងពោពេញទៅដោយក្តីស្រលាញ់ពីអ្នកដទៃជាពិសេសអ្នកបានជួយរំលែកផលលំបាកនៃចំណែកខ្លះរបស់រាជរដ្ឋាភិបាល និងដើម្បីពួកយើងដែលមានឈាមជ័រជាខ្មែរដូចគ្នា ។ខ្ញុំគិតថាអស់លោកពិតជាមិនស្អប់ខ្ពើមនូវសំដីរបស់ខ្ញុំប៉ុណ្ណឹងទេ ។

ខ្ញុំសូមបង្វែរអារម្មណ៍មិត្តអ្នកស្តាប់នូវសាច់រឿងជីវិតរបស់ខ្ញុំបន្តទៀត ។

មានពេលមួយលោកយាយខ្ញុំបានទទួលដំណឹង ថា ឪពុកមា  ម្តាយមីង និង បងប្អូនជីដូនមួយរបស់ខ្ញុំមានជីវិតរស់នៅ នៅឡើយ ។ ពួកគាត់បានរស់នៅភាគខាងលិចនៃរាជធានីភ្នំពេញដែលជាខេត្តស្រុកកំណើតរបស់ក្រុមគ្រួសារខ្ញុំ ។ដោយសារតែភាពលំបាកលំបិន និង ការនឹករលឹកកូនចៅដែលបានបែកគ្នាជាយូរ មកហើយនោះលោកយាយលោកតាបានសំរេចចិត្តអោយខ្ញុំឈប់រៀនទីនោះ ។ពួកយើងបានដាច់ចិត្តចាកចោលខ្ទមជរាដែលជាអនុស្សាវរីយ៍កំសត់ កំរ ធ្វើដំណើរដោយថ្មើរជើង ពីគីឡូម៉ែត្រលេខ៧ទៅរកជួបពួកគាត់នៅទីនោះ ។

ថ្ងៃយើងចេញដំណើ យើងមានតែបាយសំណាំពាកញ្ចប់និងត្រីប្រលាក់អាំងរួចដែល បង ប្អូនជនជាតិខ្មែរឥស្លាមបានផ្តល់អោយពួកយើងនិងទឹកមួយក្រមែល ។ថ្វីត្បិតតែការរស់នៅរបស់ពួកយើងនូវទីនោះជួបនូវការលំបាកតោកយាកយ៉ាងណាក្តីតែពួកយើងនៅតែអាលោះអាល័យស្រណោះស្រណោក រកអ្វីប្រៀបផ្ទឹមពុំបាន ។

យើងចាកចេញតាំងព្រលឹមស្រាងៗហើយការធ្វើដំណើរផ្លូវឆ្ងាយ ដោយថ្មើរជើងវាមានការហត់នឿយខ្លាំងណាស់ តែដោយការសប្បាយនិងការត្រេកអរ ចំពោះការដែលគិតថាបានជួបជុំគ្រួសារនោះ ធ្វើអោយពួកយើងភ្លេចអស់នូវភាពនឿយហត់ ។

យើងបានធ្វើដំណើរដល់ពោចិនតុង ហើយក៏នាំគ្នាសំរាក ទទួលទាននូវបាយកញ្ចប់ ។ ហូបបាយបណ្តើរលោក

យាយបានបង្ហូទឹកភ្នែកបណ្តើរហើយមានប្រសាសថា យើងផុតទុក្ខហើយចៅ ៗ សប្បាយចិត្តទេ? តែប្រសិនបើឪពុក ម្តាយ ឯងនៅរស់រានមានជីវិតដែលនោះម្ល៉េះសមពេលនេះ ឯងពិតជាបានសប្បាយនិងគេហើយ ។ប្រយោគទាំងនេះធ្វើអោយខ្ញុំអួលដើមករលេបបាយមិនរួច បានត្រឹមតែសម្រក់ទឹកភ្នែកដាក់កញ្ចប់បាយ  ។ លោកតាបានលួងលោមខ្ញុំដោយក្តីអាណិតស្រឡាញ់ដល់ចៅកំសត់ម្នាក់នេះជាពន់ពេក ។សំរាកបានបន្តិចយើងក៏បានឃើញឡានទាហានមួយ បើកតាមផ្លូវនោះលោកតាបានសុំពួកគេជិះជាមួយ ។គេក៏យល់ព្រមអោយជិះ យើងបន្តដំណើរជាមួយគេ ដោយសេចក្តីត្រេកអរជាពន់ពេក ។ ខ្ញុំចាំមិនបានច្បាស់ថាម៉ោងប៉ុន្មានទេថាខ្ញុំបានទៅដល់ទីនោះគ្រាន់តែចាំបានថាមេឃបានងងឹតណាស់ទៅហើយ ។ដល់គោលដៅយើងបានសំពះអគុណដល់ពួកទាហានហើយដើរចូលតាមផ្លូវលំនៃក្លោងទ្វារវត្តមួយសំដៅទៅជួបអ្នកទាំងនោះដោយក្តីត្រេកអរកទីបំផុតគ្មាន ។

ខ្ញុំសូមស្លេះសាច់រឿងត្រឹមប៉ុណ្ណេះសិនចុះហើយសន្យាថានិងសរសេរនូវរឿងរ៉ាវនូវជីវិតពិតរបស់ខ្ញុំបន្តទៅទៀតនៅវគ្គក្រោយប្រសិនបើអ្នកទាំងអស់ចង់ស្តាប់ហើយនិងចង់ស្គាល់ថា **តើខ្ញុំជាអ្នកណា?**

*ខ្ញុំសូមអគុណចំពោះអ្នកទាំងអស់គ្នា ហើយគិតថាសំបុត្រនេះនិងបានលឺជាលើកទី២និងជារៀងរហូត ។ មិនយូទេអ្នកនិងដឹងហើយថា* ***តើខ្ញុំជាអ្នកណា?***

វគ្គទី២នៃសំណេរ **ខ្ញុំជាអ្នកណា**

ភ្នំពេញថ្ងៃទី ៩ខែ ឧសភា ឆ្នាំ២០០៨

**ខ្ញុំជាអ្នកណា**